# ជីវប្រវត្តរបស់ អ៊ីម៉ាំ អាល់-ប្វាគقៀរ صلوات الله عليه والسلام



សៃឃីដ្ទ ម៉ាស្អ់ឌ្ទី អាយ៉ាទុលឡ្ល៍ហ៊ី

សشាគីប បេនបេឌីរ៉ា

بسم الله الرحمن الرحيم

الباقر

# បញ្ជីមាតិកា


កំណើត........................................................................................................6

របៀបរស់នៅនិងសីលធម៌របស់អ៊ីម៉ាំ...........................................................7

អ៊ីម៉ាំ អ្នកបើក អ្នកពង្រីកចំណេះវិជ្ជា...........................................................11

កិច្ចសន្ទនាជាមួយគ្រិស្តសាសនិក ...............................................................14

ការប្រលងបាញ់.............................................................................................19

ប្រាក់អ៊ីស្លាម ..................................................................................................22

សាវ័ករបស់អ៊ីម៉ាំ...........................................................................................26

ទុក្ករកម្មរបស់អ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام ..............................................30

សម្រង់ព្រះវចនៈត្រចះត្រចង់.......................................................................31

អត្តសញ្ញាណរបស់អ៊ីម៉ាំ ...............................................................................32




*-ព្រះនាមចំពោះ៖ អាល់-បាគៀរ ។*

*-ព្រះគោរពនាម៖ អាប៊ូ យ៉ាកុំហ្វារ ។*

*-ព្រះនាមព្រះបិតា៖ អាស់សាជ់យ៉ាដ់ ។*

*-ថ្ងៃប្រសូត៖ ថ្ងៃទី ១ ខែរ៉ជ៉ាប់ ឆ្នាំ ៥៧ សករាជហ៊ិជរ៉ោះត៏ ។*

*-កន្លែងប្រសូត៖ ម៉ាឌីណាស់ ។*

*-ថ្ងៃចូលទិវង្គត (ទទួលទុក្ករកម្ម)៖ ថ្ងៃទី ៧ ខែស៊ុលហ៊ិជជ៉ាស់ ឆ្នាំ ១១៤ សករាជហ៊ិជរ៉ោះត៏ ។*

*-កន្លែងបញ្ចុះព្រះរាជសព៖ ស្មសានបាគ្គីអ៊ ឯម៉ាឌីណាស់ ។*

-ព្រះអង្គ صلوات الله عليه والسلام បានប្រាប់បុត្រម្នាក់របស់ព្រះអង្គ صلوات الله عليه والسلام ថា៖ «កូនអើយ ចូរប្រយ័តការខ្ជិលច្រអូសនិងការតក់ក្រហល់ វាជាគន្លឹះនៃសេចក្ដីអាក្រក់ ។ បើកូនត្រូវការខ្ជិលច្រអូសបៀតបៀន កូនមិនអាចបំពេញកាតព្វកិច្ចណាមួយបានទេ ។ បើកូនតក់ក្រហល់ កូនមិនអាចអត់ទ្រាំបានលុះដល់សេចក្ដីសម្រេចទេ ។»

-ព្រះអង្គ صلوات الله عليه والسلام បានប្រាប់សាវកម្នាក់របស់ព្រះអង្គ صلوات الله عليه والسلام ថា៖ «ខ្ញុំសូមឲ្យយោបល់លោក ៥ ប្រការគឺ៖

-បើគេប្រព្រឹត្តមិនត្រឹមត្រូវមកលើរូបលោក ចូរកុំប្រព្រឹត្តមិនត្រឹមត្រូវលើអ្នកដទៃ ។

-បើគេក្បត់លោក ចូរលោកកុំក្បត់គេ ។

-បើគេប្រកែកជំទាស់លោក ចូរលោកកុំក្រោធ ។

-បើគេសរសើរលោក ចូរលោកចៀសវាងសេចក្ដីត្រេកអរ ។

-បើគេនិយាយមើលងាយលោក ចូរលោកកុំរំដើបរំជួល ។»

## អត្តសញ្ញាណរបស់អ៊ីមុាំ

-ព្រះនាម ៖ មូហាំម៉ាដ្ញ ។





## កំណើត

អ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام បានប្រសូតថ្ងៃទី ១ ខែរ៉ោយ៉ាប់ ឆ្នាំ ៥៧ ហ៊ិជ្រ៉េះត៍ សករាជ នៅឯម៉ាឌីណាស្ន៍ ។ ព្រះអង្គជាអ៊ីម៉ាំអាស្ន៍លុល-បៃត៍ عليهم السلام ទីប្រាំ ។ ព្រះបិតាព្រះអង្គ صلوات الله عليه والسلام គឺអ៊ីម៉ាំអ៊ាលី ប៊ិន អាល់-ហ៊ូសៃន៍ ស៊ៃនុល-អ៊ាប៊ីឌីន អាស់សាជ្ជ័យ៉ាដ្ស៍ صلوات الله عليه والسلام (علي بن الحسين زين العابدين السجاد)។ ព្រះមាតាព្រះអង្គគឺ ហ្វាទីម៉ាស្ន៍ ព្រះនត្តាស្ត្រីមួយរូបរបស់អ៊ីមាំ អាល់-ហាសាន់ អាល់-មុជ្ជតាបា صلوات الله عليه والسلام (الحسن المجتبى) ។ ដូច្នេះព្រះអង្គ صلوات الله عليه والسلام ជាអ៊ីម៉ាំអាស្ន៍លុល-បៃត៍ដំបូងបង្អស់ដែលបិតា និងមាតាទាំងពីរជារាជបុត្ររាជនត្តា عليهم السلام របស់ព្រះសាស្តា صلى الله عليه وآله وسلم ។

ព្រះនាមរបស់អ៊ីម៉ាំគឺមូហាំម៉ាដ្ស៍ ។ ព្រះនាមចំតើតរបស់ព្រះអង្គ صلوات الله عليه والسلام គឺ អាល់-បាគៀរ ដែលមានន័យជាភាសាអារ៉ាប់ថា "អ្នកបើក" និង "អ្នកពង្រីក" ។ យោលតាម យ៉ាបៀរ អ៊ីបនូ អ៊ាប់ឌុលឡោះហ្ន៍ សាវករបស់ព្រះសាស្តា صلى الله عليه وآله وسلم ព្រះសាស្តា صلى الله عليه وآله وسلم ព្រះសាស្តា صلى الله عليه وآله وسلم ជាអ្នកជ្រើសរើសឈ្មោះនេះដាក់ឲ្យព្រះអង្គ صلوات الله عليه والسلام ។ ព្រះសាស្តា صلى الله عليه وآله وسلم មានព្រះវចនៈដោយចង្អុលអ៊ីម៉ាំអាល់-ហ៊ូសៃន៍ صلوات الله عليه والسلام ថា៖ « អ៊ាលីនឹងប្រសូតចេញមកពីម្នាក់នេះ ដែលគេនឹងហៅនាថ្ងៃជំនុំជម្រះថា ម្ចាស់របស់អ្នកមានសទ្ធាជ្រះថ្លា ។ បុរសដែលនឹងបើកនិងពាត



ត្រឡប់ទៅជួបជុំបុព្វការី عليهم السلام ព្រះអង្គ صلوات الله عليه والسلام នៅឯឋានសួគ៌ ក្បែរព្រះម្ចាស់ عز وجل លោកទាំងពួង ។

អ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام បានគង់នៅ ៥៧ វស្សាក្នុងការបម្រើសាសនាអ៊ីស្លាម ។ ក្នុងអំឡុងពេល ៥៧ ឆ្នាំនេះព្រះអង្គ صلوات الله عليه والسلام បានថែរក្សាព្រះរាជសារពីការកែបំភ្លៃ បានអភិរក្សព្រះរាជបញ្ញត្តិមិនឲ្យភ្លេចប្តូរធ្វេស ។

សូមអល់ឡោះហ្ន៍ عز وجل ប្រទានពរជ័យសិរីសួស្តីដល់ព្រះអង្គ صلوات الله عليه والسلام និង អាស្ន៍លុល-បៃត៍ عليهم السلام ទាំងឡាយ ។

## សម្រង់ព្រះវចនៈត្រចះត្រចង់

-អ្នកមានសទ្ធាដឹងខ្លួនថាវិចារណញ្ញាណរបស់ខ្លួនអន់ថយ ពេលខ្លួនមានចិត្តឡឹតក្រអឺត ។

-អ្នកប្រាជ្ញម្នាក់ដែលផ្តល់ចំណេះចេះដឹងដល់អ្នកដទៃ ប្រសើរជាងអ្នកមានសទ្ធាមួយពាន់នាក់ ។ សូមស្បថចំពោះអល់ឡោះហ្ន៍ عز وجل សម្រាប់អ៊ីបលីស لعنه الله មរណភាពរបស់អ្នកប្រាជ្ញម្នាក់ គ្រាន់ជាងមរណភាពរបស់អ្នកមានសទ្ធាចិតសិបនាក់ ។

សូមស្នេះត្រឹមនេះ នៅមានលោកអ្នកប្រាជ្ញច្រើនរូបទៀត ។

## ទុក្ករកម្មរបស់អ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام

អ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام មិនគិតដល់ការប្រយុទ្ធ ដណ្តើមអំណាចឡើយ ។ ព្រះអង្គ صلوات الله عليه والسلام លះបង់ជីវិតព្រះអង្គ صلوات الله عليه والسلام ដើម្បីចំណេះវិជ្ជា ដើម្បីបង្ហាត់បង្រៀនវិន័យអ៊ីស្លាមនិងសិក្ខាបទរបស់ព្រះអង្គ صلوات الله عليه والسلام ឆ្ងាយពីចលនានយោបាយនិងឆ្ងាយពីការជ្រួលច្របល់ ដែលអង្រួនបល្ល័ង្កអ៊ូម៉ៃយ៉ាស្ហ៍ឥតឈប់ឈរ ។ ទោះជាយ៉ាងណាក៏ដោយ បុគ្គលកាន់អំណាចផ្តាច់ការនៃនគរដ្ឋាម៉ាស់មិនអាចអត់ទ្រាំវត្តមានអ៊ីម៉ាំតទៅទៀតបានទេ ព្រមទាំងកេរ្តិ៍ឈ្មោះព្រះអង្គដែលចេះតែខ្ពរខ្ពាយរាតទីកាន់តែធំទៅៗ ។ ដូចបុគ្គលឧក្រិដ្ឋ គ្មានការខ្មាស់អៀនមុនៗដែរ ស្តេចអ៊ូម៉ៃយ៉ាស្ហ៍បានបញ្ជាឲ្យដាក់ថ្នាំបំពុលអ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام ដោយគិតខុសថាបទឧក្រិដ្ឋរបស់ខ្លួននឹងអាចរំលំវិជ្ជាដ្ឋានរបស់អ៊ីម៉ាំបាន វិជ្ជាដ្ឋានដែលអាចធ្វើឲ្យសំណាក់មុស្លីមអាចដកខ្លួនចេញទៅរកសេរីភាពវិញបាន បណ្តាលឲ្យមនុស្សទូទៅភ្ញាក់ខ្លួនឡើងវិញហើយរំលំរបបផ្តាច់ការសោហាវយង់ឃ្នងរបស់បុគ្គលបោកប្រាស់ត្រកូលអ៊ូម៉ៃយ៉ាស្ហ៍ ។

ថ្ងៃទី ៧ ខែស៊ុលហ៊ិជ្ជយ៉ាស្ហ៍ ឆ្នាំ ១១៤ អ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام បានវិល



ពង្រីកការចេះដឹងនឹងប្រសូតមកពីម្នាក់នេះ ។ យ៉ាប៉ៀរអើយ បើលោកបានជួបគេ សូមលោកគំនាប់គេជួសខ្ញុំផង ។»

## របៀបរស់នៅនិងសីលធម៌របស់អ៊ីម៉ាំ

អ៊ីម៉ាំមូហាំម៉ាដ្ឋ អាល់-បាគៀរ صلوات الله عليه والسلام មានព្រះជន្មាយុ ៤ ខួបកាលសោកនាដកម្មការបាឡាអ៊ុំបានកើតឡើង ។ ព្រះអង្គ صلوات الله عليه والسلام បានរស់នៅ ៣៥ ឆ្នាំក្រោមការទំនុកបម្រុងរបស់ព្រះបិតា صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام ។ បន្ទាប់ពីនោះព្រះអង្គ صلوات الله عليه والسلام បានទៅជាអ៊ីម៉ាំរបស់សំណាក់មុស្លីមអស់រយៈពេល ១៨ ឆ្នាំ ។

នៅក្នុងដំណើរជីវិតដ៏ខ្លីនេះ អ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام ក៏ដូចអ៊ីម៉ាំមុនៗព្រះអង្គ صلوات الله عليه والسلام ដែរ គឺមានគំរូសុក្រឹតគ្រប់វិស័យហើយព្រះអង្គ صلوات الله عليه والسلام នៅចំកណ្តាលព្រឹត្តិការណ៍ទាំងឡាយដែលប្រកបដោយទុក្ខវេទនា ។

សូមបញ្ជាក់ថាព្រះអង្គ صلوات الله عليه والسلام មានជីវិតរស់នៅសាមញ្ញបំផុត ក្នុងសម័យដែលពួកធំដុំអាក៉ប់ទាំងអស់រស់នៅក្នុងភាពសម្បូរហូរហៀរ ទោះជាព្រះអង្គ صلوات الله عليه والسلام អាចរស់នៅក្នុងភាពឥតខ្វល់ខ្វាយ ខ្ជិលច្រអូស ក៏ដោយ ។ មែន ទោះជាព្រះអង្គ صلوات الله عليه والسلام មានចម្ការនិងតំបន់ដំណាំច្រើនក៏ដោយ ព្រះអង្គ صلوات الله عليه والسلام បំពេញកិច្ចការស្រែចម្ការដោយដៃឯង និងចូលរួមជាមួយកម្មករកសិករទាំងឡាយ





**-ស៊ូរ៉ោះត៍ ប៊ិន អាយុន** (زرارة بن أعين) ។ លោកមានដើមកំណើតជាគ្រិស្តសាសនិក ។ លោកបានសិក្សាគួរអានហើយបានកាន់ជាប់នូវសាសនារបស់មូហាំម៉ាដ់ صلى الله عليه وآله وسلم ព្រះសាស្តារបស់អល់ឡោះហ៍ عز وجل ។ លោកជាអ្នកប្រាជ្ញដ៏ល្បីមួយរូបនិងជាអ្នកជំនាញខាងច្បាប់ ។ គេស្គាល់លោកជាបុគ្គលដែលខ្លាចអល់ឡោះហ៍ عز وجل ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុត ។

**-បារីដុ ប៊ិន មូអ៊ារីយ៉ាស់ អាល់-អ៊ាយ៉ាលី** (بريد بن معاوية العجلي) ។ លោកជាសិស្សឆ្នើមមួយរូបរបស់អ៊ីមុាំអាល់-បាគៀរ صلوات الله عليه والسلام ដែលទទួលមរណៈភាពនាសម័យអ៊ីមុាំអាស់ស្វ័ឌិក្ក صلوات الله عليه والسلام ។

**-មូហាំម៉ាដ់ ប៊ិន មុស្លឹម។** លោកជាអ្នកជំនាញច្បាប់អ៊ីស្លាមដ៏ពូកែមួយរូប ។ លោកបានធ្វើសេចក្តីរាយការណ៍ សម្តីរបស់អ៊ីមុាំអាល់-បាគៀរ صلوات الله عليه والسلام ៣០០០០ សម្តី សម្តីរបស់អ៊ីមុាំអាស់ស្វ័ឌិក្ក ១៦ ០០០ សម្តី ។

**-អាប៊ូ បាស្វៀរ** (ابو بصير) ។ អាប៊ូ បាស្វៀរជាអ្នកប្រាជ្ញដែលមានជំនឿស៊ប់ចិត្តមួយរូប ។ លោកបានផ្សាយសម្តីរបស់អ៊ីមុាំទាំងពីរអង្គ عليهم السلام បានថែរក្សាកេរដំណែលវិទ្យាសាស្ត្ររបស់អាស់លុល-បៃត៍ عليهم السلام ។ លោកជាទស្សនវិទូអ៊ីស្លាមដ៏ល្បីមួយរូប ។

ដូច្នេះឯង បានជាមុស្លីមដែលមានសំណាងក្លាយទៅជាសិស្សរបស់អ៊ីម៉ាំ صلوات الله عليه والسلام មានចំនួនលើសពីរបីពាន់នាក់ ។ នេះគឺព្រឹត្តិការណ៍ថ្មីមួយដែលទើបនឹងមានឡើងនៅក្នុងប្រវត្តិសហគមន៍មុស្លីម ។ តែភាពជាសិស្សរបស់អ៊ីម៉ាំខុសពីភាពសាវកភក្តីរបស់អ៊ីម៉ាំ ។ អ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام ដឹងច្បាស់ថាព្រះអង្គ صلوات الله عليه والسلام មិនអាចទុកចិត្តលើនិស្សិតទាំងអស់ ដែលមានវត្តមានក្នុងសាលាព្រះអង្គ صلوات الله عليه والسلام នោះបានទេ ។ ព្រះអង្គ صلوات الله عليه والسلام ជ្រើសរើសយកតែមួយចំនួនតូចដើម្បីទទួលបេសកកម្ម ជាគ្រូបង្រៀនរបស់មហាវិទ្យាល័យវិទ្យាសាស្ត្រអាស្ហ់លុល-បៃត៍ដំបូងបង្អស់ ។ យើងលើកឡើងនូវសិស្សល្បីៗមួយចំនួនរបស់អ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام គឺមានៈ

**-អាបាន ប៊ិន តាក់លុប** ។ លោកជាអ្នកស្រុកគូហ្វាស្ហ់ លោកបានស្គាល់អ៊ីម៉ាំអាស់សាច់យ៉ាដ់ صلوات الله عليه والسلام អ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام និងអ៊ីម៉ាំអាស់សាឌិក صلوات الله عليه والسلام ហើយបានធ្វើសេចក្តីរាយការណ៍ ៣០ ០០០ សម្តីរបស់អ៊ីម៉ាំទាំងពីរអង្គនេះ ។ លោកជាម្នាក់ដែលចេះហាឌីស ចេះភាសាអារ៉ាប់និងចេះបកស្រាយគួរអាន យ៉ាងជ្រៅជ្រះ ។ លោកជាបុគ្គលឆ្នើមមួយរូបដែលបានលះបង់ខ្លួនដើម្បីសាសនាអ៊ីស្លាម ។



របស់ព្រះអង្គ صلوات الله عليه والسلام ក្នុងការបរិភោគអាហារសាមញ្ញរបស់ពួកគេ ។ រៀងរាល់ឆ្នាំព្រះអង្គ صلوات الله عليه والسلام ចំណាយប្រាក់ចំណូល ដែលសល់ពីសេចក្តីត្រូវការទៅលើជនក្រីក្រតោកយ៉ាក ។ ដូច្នេះឯងបានជាព្រះអង្គ صلوات الله عليه والسلام ល្បីកេរ្តិ៍ឈ្មោះជាបុគ្គលដែលមានចិត្តសប្បុរសទូលំទូលាយបំផុតក្នុងសម័យព្រះអង្គ صلوات الله عليه والسلام ។

ដែលអ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام បំពេញកិច្ចការស្រែចម្ការ ដោយដៃព្រះអង្គ صلوات الله عليه والسلام ឯង កិច្ចការដែលព្រះអង្គ صلوات الله عليه والسلام អាចទុកឲ្យពួកកម្មករបំពេញនោះ គឺដើម្បីបង្ហាញគំរូដល់មុស្លីមទាំងអស់ ដែលកំពុងតែរស់នៅក្នុងសម័យមួយដែលកំពុងតែទេរទៅរករបៀបរស់នៅដោយមិនប្រកបកិច្ចការអ្វីសោះ ហើយដែលកំពុងតែបើកដៃឲ្យការខ្ជិលច្រអូសហូរចូលមកក្នុងរបៀបរស់នៅ ។

អំណាចអ៊ូម៉ៃយ៉ាស្ហ់ កាលនោះកំពុងតែចាក់ឫសកែវយ៉ាងមាំ បានរាតពង្រីកមូលដ្ឋានខ្លួនឆ្ងាយពីត្រកូលអ៊ូម៉ៃយ៉ាស្ហ់ដោយចែកដី និងស្រែចម្ការឲ្យទៅពួកអភិជនអារ៉ាប់ ដែលភាគច្រើនមិនមានចំណេះវិជ្ជាវិស័យកសិកម្មបន្តិចបន្តួចឡើយ ។ ដូច្នេះជនទាំងនេះរស់នៅជាជនលាភី(ចាំតែទទួលផលស្រាប់ៗ) ឥតប្រកបកិច្ចការអ្វីសោះ ។

តម្លៃសង្គមដែលសំណាក់អ៊ូម៉ៃយ៉ាស្ហ់ដះមកលើមនុស្សសម័យនោះ បាន

ឈានដល់កម្រិតមួយគឺ៖ ការងារហត្ថកម្មអាចធ្វើឲ្យប៉ះពាល់ដល់ឋានៈសក្តិយសរបស់អភិជនអ្នកធំដុំ ។

បុគ្គលមួយចំនួនគិតថាការកាន់វត្តប្រតិបត្តិតឹងរ៉ឹង គ្រាន់តែការលោភលន់ទន់ទេរទៅរកការកើបយកទ្រព្យឲ្យកាន់តែច្រើនឡើង ។ បុគ្គលប្រភេទនេះម្នាក់ដែលមានឈ្មោះថា មូហាំម៉ាដ់ អាល់-មុនកាឌៀរ បានធ្វើសេចក្តីរាយការណ៍ប្រាប់យើងដោយផ្ទាល់អំពីជំនួបជាមួយអ៊ីមុាំអាល់-បាគៀរ صلوات الله عليه والسلام ដែលបានកែតម្រង់ទស្សនៈ និងការយល់ឃើញរបស់លោកពាក់ព័ន្ធនឹងការងារហត្ថកម្ម ។

កាលលោកបានឃើញអ៊ីមុាំអាល់-បាគៀរ صلوات الله عليه والسلام កំពុងតែធ្វើការក្នុងចម្ការ លោកបានគិតភ្លាមថា នេះគ្រាន់តែជាការបញ្ជាក់ឲ្យឃើញនូវសេចក្តីលោភលន់ប៉ុណ្ណោះដែលលោកគួរតែប្រដែប្រដៅ ។ លោកក៏បានដើរចូលទៅរកព្រះអង្គ صلوات الله عليه والسلام ដើម្បីបំពេញតាមគម្រោងគំនិតលោក ដោយសម្តែងអាកប្បកិរិយាមិនយល់ស្រប ដែលឃើញអភិជនគួរយ៉ស្ទុំដូចព្រះអង្គ صلوات الله عليه والسلام ធ្វើការដូច្នេះ ។ តែចម្លើយរបស់អ៊ីមុាំ صلوات الله عليه والسلام ជាមេរៀនមួយមិនអាចភ្លេចបានសម្រាប់លោក ។ ព្រះអង្គ صلوات الله عليه والسلام បានពន្យល់លោកថា ការងារព្រះអង្គ صلوات الله عليه والسلام





ផ្ទះថ្វា ។ ពួកគេបានធ្វេសប្រហែស មិនបានក្រេបយកចំណេះប្រាជ្ញាមហាសាលពីអ៊ីម៉ាំរបស់ពួកគេទេ ដែលតែងតែមានវចនៈថា៖ «សួរខ្ញុំមកមុននឹងអស់លោកបាត់បង់ខ្ញុំ ។»

ជនទាំងនេះចេះឆ្មៀតយកផលប្រយោជន៍ ពីវត្តមានរបស់អ៊ីម៉ាំដែលប្រកបដោយសេចក្តីទំនុកបម្រុងនិងសប្បុរសធម៌ ។ ពួកគេមកពីគ្រប់ទិសទីដែលនៅក្នុងចំណុះខ៊ីលីហ្វាស់ មកជុំគ្នានៅឯម៉ាស់យ្ជិដព្រះសាស្តា صلى الله عليه وآله وسلم មកក្រាបប្រណិប័តន៍ម្ចាស់និងព្រះបរមគ្រូរបស់ពួកគេ ម្ចាស់ចំណេះប្រាជ្ញាដ៏វិសេសវិសាល អ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام ។

## សាវ័ករបស់អ៊ីម៉ាំ

ខណៈដែលអាជ្ញាអ៊ូម៉ៃយ៉ាស់ រវល់តែបង្ក្រាបការរំដើបរំជួលនិងការបះបោររបស់សំណាក់មូស្លីមនៅតាមតំបន់ចំណុះខ៊ីលីហ្វាស់នានា នគរម៉ាឌីណាស់បានក្លាយទៅជារាជធានីពិតៗរបស់ពិភពអារ៉ាប់ទាំងមូល បន្តិចម្តងៗ ដោយសារវត្តមានរបស់អ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام ។ ព្រះអង្គ صلوات الله عليه والسلام មានកេរ្តិ៍ឈ្មោះល្បីល្បាញជាទីបំផុត ។ ក្លាយទៅជាសិស្សម្នាក់របស់ព្រះអង្គ صلوات الله عليه والسلام ជាសេចក្តីសុបិនរបស់យុវជនអ៊ីស្លាមគ្រប់រូប ដែលស្រេកឃ្លានចំណេះវិជ្ជា ។



ជាការគោរពសក្ការៈអល់ឡោះហ៍ عز وجل ព្រះអង្គ صلوات الله عليه والسلام សុខចិត្តស្លាប់នៅក្នុងសភាពបែបនេះ ។

សេចក្តីរាយការណ៍របស់អ៊ីបនូ អាល់-មុនកាឌៀរលើកឡើងនូវមេរៀនពីរ គឺ៖ ជាដំបូង ការងារហត្ថកម្មធ្វើឲ្យមនុស្សមានសេចក្តីថ្លៃថ្នូរកាន់តែច្រើនឡើងបន្ទាប់មក ជាពិសេសត្រូវពឹងពាក់លើខ្លួនឯង មិនត្រូវរស់នៅដោយពឹងលើអ្នកដទៃជាដាច់ខាត មិនត្រូវទទួលយកអំណោយឬទានដែលគេឲ្យទេ ដូចបុគ្គលមួយចំនួនដែលតាំងខ្លួនជាអ្នកកាន់វត្តប្រតិបត្តិតឹងរ៉ឹង ឬជាតាបសក្នុងសម័យនោះ ។

អ៊ីបនូ អាល់-មុនកាឌៀរជាបាវបម្រើមួយរូបរបស់អល់ឡោះហ៍ عز وجل ។ ដូច្នេះមេរៀននេះបានផ្តល់នូវផលប្រយោជន៍ល្អសម្រាប់លោក ។

## អ៊ីម៉ាំ អ្នកបើក អ្នកពង្រីកចំណេះវិជ្ជា

កាលអ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام បានគង់នៅឯម៉ាស់យ្ជិដរ៉ស៊ូលុលឡោះហ៍ صلى الله عليه وآله وسلم ដើម្បីបង្ហាត់បង្រៀនមូស្លីមទាំងឡាយឲ្យចេះដឹងសិក្ខាបទអ៊ីស្លាម មូស្លីមទាំងឡាយមិនដែលបានដឹងឮលើសពីការតំណាល ឬលើសពីការសូត្រនូវ

ហ្វាឌីស្សបុអាយ៉ាត់គួរអានទេ ។ ពួកអ្នកប្រាជ្ញសម័យនោះតែងតែប្រើវិធីនេះ ដើម្បីឆ្លើយតបសំណួរ ។ អ៊ីមាំអាល់-បាគៀរ صلوات الله عليه والسلام បានប្រារព្ធទំព័រថ្មីមួយក្នុង ប្រវត្តិសាស្ត្រនៃវិទ្យាសាស្ត្រអ៊ីស្លាម ដោយយកមកប្រើឡើងវិញនូវការសិក្សា ច្រើនមុខវិជ្ជាដែលអាលី صلوات الله عليه والسلام ព្រះអយ្យកោ صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام បាន បង្ហាញរួចមកហើយ ។

ព្រះនាមចំតើតបាគៀរ អ្នកបើក អ្នកពង្រីកចំណេះវិជ្ជា បានលេចពុពីមាត់ មួយទៅត្រចៀកមួយ ។ សូម្បីតែពួកសត្រូវនិងគូប្រឆាំងរបស់អាស្ហ៊លុល-បៃត៍ក៏មកចូលសូមសិក្សាពីព្រះអង្គ صلوات الله عليه والسلام ដែរ ។ អ៊ីមុាំអាល់-បាគៀរ صلوات الله عليه والسلام មានព្រះហឫទ័យសប្បុរសជានិច្ច ។ ព្រះអង្គ صلوات الله عليه والسلام មិនបដិសេធអ្នកសូម ចំណេះឡើយ ទោះជាអ្នកនោះមិនសមនឹងបានចំណេះនោះក៏ដោយ ។ ប្រវត្តិសាស្ត្របានលើកឡើងនូវច្រើនព្រឹត្តិការណ៍ ដែលបង្ហាញឲ្យឃើញនូវ ចរិយាប្រកបដោយសប្បុរសធម៌របស់អ៊ីមុាំអាល់-បាគៀរ صلوات الله عليه والسلام ។ ដូចជារឿងរ៉ាវរបស់បុរសស៊ីរីម្នាក់ជាដើម ដែលបានមកសូមសិក្សាពីព្រះអង្គ صلوات الله عليه والسلام ដោយបញ្ជាក់ថាគាត់មិនចូលចិត្តអាស្ហ៊លុល-បៃត៍ عليهم السلام ទេ ។ គាត់មិន ដែលបិទបាំងសេចក្តីស្អប់ខ្ពើមនេះទេ គាត់បានសម្តែងឲ្យគេឯងបានឃើញ



صلوات الله عليه والسلام បានបញ្ជាក់ប្រាប់យ៉ាងរហ័ស ឲ្យខ៊ុលិហ្វអនុវត្តន៍តាមវិធីដោះស្រាយ ដូចតទៅគឺ៖ ប្រមូលមាសនិងប្រាក់ឲ្យបានគ្រប់គ្រាន់មកពីគ្រាប់តំបន់និង អាណាខេត្តទាំងឡាយដែលនៅក្រោមចំណុះខ៊ុលីហ្វាស្ញ បន្ទាប់ពីនោះឲ្យបោះ ពុម្ភប្រាក់អ៊ីស្លាមដើម្បីជាជំនួសប្រាក់ប៊ីសង់ ។ អ៊ីមុាំ صلوات الله عليه والسلام ថែមទាំងបាន បញ្ជាក់ប្រាប់នូវទម្ងន់ប្រាក់ និងលាយលក្ខណ៍អក្សរសមរម្យដែលត្រូវចារនៅ លើប្រាក់ថ្មីនោះទៀតផង ។ ពួកគេក៏បានរួចផុតពីគ្រោះថ្នាក់ពីសំណាក់ ប៊ីសង់ ។ ព្រះចៅអធិរាជបានវាយលុកយ៉ាងរួសរាន់មកលើខ៊ុលិហ្វ តែបន្ទាប់ មកក៏បានបញ្ជាឲ្យដកថយវិញហើយបានទទួលស្គាល់បរាជ័យ ។

ព្រឹត្តិការណ៍នេះជាឱកាសមួយសម្រាប់សំណាក់មុស្លីម ដើម្បីយល់ដឹងនូវ តម្លៃរបស់អ៊ីមុាំអាល់-បាគៀរ صلوات الله عليه والسلام អ្នកស្នងព្រះអភិញ្ញាដែលធ្លាប់បានមក លើព្រះអយ្យកោ صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام ព្រះអគ្គមហាប្រមុខ صلوات الله عليه والسلام របស់អ្នក មានសទ្ធាជ្រះថ្លា រួចមកហើយ ។

មនុស្សជំនាន់អ៊ីមុាំអាល់-បាគៀរ صلوات الله عليه والسلام យកចិត្តទុកដាក់នឹងចំណេះប្រាជ្ញា ជាងជនជំនាន់មុនៗ ហាក់ដូចជាបដិសេធអាកប្បកិរិយាដែលគួរឲ្យអៀនខ្មាស របស់ជនមុនៗ ដែលជាជនដំណាលព្រះអគ្គមហាប្រមុខរបស់អ្នកមានសទ្ធា

ព្រះចៅអធិរាជប៊ីសង់បានដាក់ឱសានវាទលើម៉ារវ៉ាន បង្ខំឲ្យម៉ារវ៉ានប្រគល់ទឹកដីជម្លោះនោះមកឲ្យខ្លួនវិញ ។ ពុំនោះទេសំណាក់មុស្លីមនឹងលែងប្រើប្រាក់ប៊ីសង់បានតទៅទៀត ។ ទើសទាល់ខ្លាំង មានបារម្ភជាទម្ងន់ ម៉ារវ៉ានបានសួរយោបល់ពីសំណាក់បរិវារនិងសំណាក់អភិជនជាតិស៊ីរី ។ ព្រោះតែស្ថានការណ៍នេះចម្លែកពេកនិងមិនដែលបានគិតទុកជាមុន បានជាទីប្រឹក្សាទាំងអស់របស់ខ៊ូលិហ្វប្រកាសចាល់គំនិត ឥតមធ្យោបាយដោះស្រាយបញ្ហានេះ ហើយបានប្រាប់ព្រះចៅខ៊ូលិហ្វរបស់ខ្លួនថា បុគ្គលម្នាក់គត់នៅលើផែនដីដែលជាម្ចាស់ឃ្លាំងចំណេះប្រាជ្ញាគឺបុរសអ្នកបើក អ្នកពង្រីកចំណេះប្រាជ្ញា គឺអ៊ីមុាំអាល់-បាគៀរ صلوات الله عليه والسلام ។

ដូច្នេះ អ្នកនាំសាររបស់ខ៊ូលិហ្វក្លែងក្លាយបានមកជួបអ៊ីមុាំស្របច្បាប់របស់សហគមន៍មុស្លីម សូមឲ្យព្រះអង្គ صلوات الله عليه والسلام ជួយផ្តល់យោបល់ដើម្បីដោះស្រាយបញ្ហាដែលព្រះចៅខ៊ូលិហ្វកំពុងតែប្រឈម ។ អ៊ីមុាំអាល់-បាគៀរ صلوات الله عليه والسلام យល់ភ្លាម់ថា ពុំមែនអំណាចរបស់សម្តេចអ៊ូម៉ៃយ៉ាស្ទូទេដែលកំពុងតែស្ថិតនៅក្នុងភាពជ្រួលច្របល់ តែកិត្តិយសរបស់រដ្ឋអ៊ីស្លាមនោះទេដែលនឹងត្រូវអាម៉ាស់ធំនឹងជះឥទ្ធិពលអាក្រក់មកលើកិត្យានុភាពរបស់សាសនាអ៊ីស្លាម ។ ព្រះអង្គ





យ៉ាងក្រអឺតងងើល លុះថ្ងៃមួយគាត់បានធ្លាក់ខ្លួនឈឺ ។ អ៊ីម៉ាំ صلوات الله عليه والسلام បានទៅមើលគាត់ បានប្រាប់គាត់នូវវិធីផ្សំថ្នាំដែលបានធ្វើឲ្យបានជាសះស្បើយពីជម្ងឺ ។ នៅទីបំផុត បុរសជាតិស៊ីរីបានទៅជាសាវកមួយរូបរបស់អ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام ។

នាសម័យអ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام កូនច្រើននាក់របស់សាវកព្រះសាស្ដា صلى الله عليه وآله وسلم បានតាំងខ្លួនជាអ្នកចេះដឹង តែជាញឹកញាយពួកគេពុំមានសមត្ថភាពទេ ។ ពួកគេមកកាន់ម៉ាស់យ៊ិដ្ឌរ៉ស៊ូលុលឡោះហ្វ៍ صلى الله عليه وآله وسلم ដើម្បីបង្ហាត់បង្រៀន និងឆ្លើយសំណួរគេ ។ ម្នាក់មានឈ្មោះថា អ៊ាប់ឌុលឡោះហ្វ៍ ប៊ិន អ៊ុំម៉ារ ប៊ិន អាល់-ខត្តត្តប់ ។ ថ្ងៃមួយគាត់បានចាល់សំណួរអ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام ឆ្លើយព្រះអង្គ صلوات الله عليه والسلام មិនរួច ។ គាត់បានចង្អុលអ៊ីម៉ាំ صلوات الله عليه والسلام ឲ្យអ៊ីម៉ាំ صلوات الله عليه والسلام ទៅនាំយកចម្លើយនោះមកឲ្យគាត់ ។ លុះបានទទួលចម្លើយ អ៊ាប់ឌុលឡោះហ្វ៍ ប៊ិន អ៊ុំម៉ារ បានថាៈ « នេះកូនរបស់ត្រកូលមួយដែលគេបានប្រាប់ឲ្យយល់ដឹងសព្វសារពើ ។»

## កិច្ចសន្ទនាជាមួយគ្រិស្តសាសនិក

ដូចអ៊ីម៉ាំអ៊ាលី ប៊ិន អាប៊ូ ត្ត៏លិប صلوات الله عليه والسلام ដែរ អ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام ជាបុគ្គល





អញបានជ្រើសរើសយកអ៊ីស្លាមជាសាសនាសម្រាប់ពួកអ្នក(ស៊ូ.៥ អា.៣) ។»

ទប់តំហឹងមិនបាន ហ៊ីស្សាំបានថា៖ «ពួកអ្នកឯងបានចំណេះនេះមកពីណា អត់ពីមូហាំម៉ាដ់ صلى الله عليه وآله وسلم ទៅ មិនមានសាស្ដាទេ ។ អ្នកឯងមិនមែនសាស្ដាទេ?» អ៊ីម៉ាំមានវចនៈថា៖ «យើង صلوات الله عليه والسلام ទទួលចំណេះនោះមកពីព្រះអយ្យកោ صلوات الله عليه والسلام យើង អាលី صلوات الله عليه والسلام ដែលមានវចនៈថា៖ “ព្រះសាស្ដាអល់ឡោះហ៊្វ صلى الله عليه وآله وسلم បានបង្ហាត់បង្រៀនខ្ញុំ صلوات الله عليه والسلام រាប់ពាន់ជំពូកចំណេះ ចំពូកនីមួយៗមានរាប់ពាន់ចំពូកទៀត ។” ហ៊ីស្សាំចុកមាត់ និយាយមិនរួច ។ ខ្លាចប្រជារាស្ដ្រស៊ីរីមានទំនាក់ទំនងជាមួយអ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام ដើម្បីក្រេបយកនូវចំណេះវិជ្ជានិងគតិប្រាជ្ញាព្រះអង្គ صلوات الله عليه والسلام ហ៊ីស្សាំបានបញ្ជាឲ្យនាំអ៊ីម៉ាំទៅកាន់ម៉ាឌីណាស្ងួវិញ ។

## ប្រាក់អ៊ីស្លាម

រហូតមកដល់សម័យអាប់ឌុល-ម៉ាលិក ប៊ិន ម៉ារវ៉ាន ប្រាក់ធម្មតាដែលពួកមុស្លីមប្រើគឺប្រាក់ប៊ីសង់(Byzance) ។ នាសម័យបុគ្គលអ៊ូម៉ៃយ៉ាស្ទ់ឃោរឃៅរូបនេះ ការប្រយុទ្ធគ្នារឿងព្រំប្រទល់បានកើតឡើង រវាងសំណាក់អ៊ូម៉ៃយ៉ាស្ទ់និងអាណាចក្រប៊ីសង់ ។ ព្រះចៅអធិរាជប៊ីសង់មានបំណងប្រើអាវុធសេដ្ឋកិច្ច ។ ព្រោះតែគិតថាសំណាក់មុស្លីមមិនអាចចៀសវាងប្រើប្រាក់បាន





មួយគត់ដែលអាចជាតំណាងសាសនាអល់ឡោះហ៍ عزّ وجلّ បានយ៉ាងបរិបូរ ដែលអាចឆ្លើយតបសំណួរទាំងអស់បានពីគ្រប់ទិសទី ដែលផុះមកពីគ្រប់ផ្នត់គំនិតរបស់មនុស្ស ។

ផ្ទុយពីពួកអ្នកកាន់សាសនាគ្រិស្តនៃឧបទ្វីបអារ៉ាប់ ដែលប្តូរសាសនាមកកាន់សាសនាអ៊ីស្លាមជាញឹកញយ គ្រិស្តសាសនិកនៃប្រទេសស៊ីរីមិនមានឱកាសទាក់ទងអ៊ីម៉ាំអាស្ហ៍លុល-បៃត៍ និងសាវ័ករបស់ព្រះអង្គបានទេ ។ ព្រោះតែនៅក្បែររាជធានីនៃអាណាចក្រអ៊ូម៉ៃយ៉ាស្ហ៍ពេក បានជាពួកគេមិនបានស្គាល់ច្បាស់លាស់នូវជម្រៅពិតរបស់សាសនាអ៊ីស្លាម ដែលពុំមែនជាសាសនាសម្រាប់ធ្វើឲ្យព្រះចៅអធិរាជទាំងឡាយទៅជាស្របច្បាប់ ឬធ្វើឲ្យទង្វើរបស់ព្រះចៅអធិរាជទៅជាត្រឹមត្រូវសមស្របតាមច្បាស់នោះទេ ។

ការធ្វើដំណើររបស់អ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام ជាមួយអ៊ីម៉ាំអាស្ហ៍ស្ហ៊ឌិក្ក صلوات الله عليه والسلام បុត្ររបស់ព្រះអង្គ صلوات الله عليه والسلام ទៅកាន់ប្រទេសស៊ីរី ទោះជាព្រះអង្គ صلوات الله عليه والسلام នៅក្រោមសម្ពាធខ៏លិហ្វអ៊ូម៉ៃយ៉ាស្ហ៍ក៏ដោយ ជាឱកាសល្អមួយសម្រាប់គ្រិស្តសាសនិកនៃតំបន់នេះ ដើម្បីមកទាក់ទងតំណាងសុក្រឹតរបស់សាសនាអ៊ីស្លាម ។ សេចក្តីរាយការណ៍តទៅនេះជាភ័ស្តុតាងច្បាស់ក្រឡែត ។



មុខអស់អភិនពពាក់ពពូនគ្នា ដែលមកពីគ្រប់ទិសទី ។ អ៊ីម៉ាំយល់ហេតុការណ៍ក៏បានចាប់ធ្នូហើយបាញ់គ្រាប់ព្រួញដំបូងចំកណ្តាលរង្វង់ គ្រាប់ទីពីរចំគ្រាប់ទីមួយ គ្រាប់ទីបីចំគ្រាប់ទីពីរ លុះបានបាញ់អស់ប្រាំបួនគ្រាប់ គ្រាប់មួយលើគ្រាប់មួយ បណ្តាលឲ្យមនុស្សម្នាស្ងើយ ឯហ៊ីស្ហ៊ាំមិនអាចបដិសេធបានឡើយ ។

ហ៊ីស្ហ៊ាំខំស្តារស្ថានភាព ដោយប្រកាសចំពោះមហាជនថាអ៊ីម៉ាំជាវីរៈបុរសរបស់គូរ៉ៃស្ហ៍មួយរូប និងដោយសម្តែងឲ្យឃើញនូវសេចក្តីត្រេកអរចំពោះស្នាដៃឆ្នើមរបស់បងប្អូនខ្លួនដែលជាបានី-ហាស្ហ៊ីម ។ ហ៊ីស្ហ៊ាំបានអញ្ជើញអ៊ីម៉ាំអង្គុយជិតខ្លួន ហើយបានសួរព្រះអង្គ صلوات الله عليه والسلام ថា៖ « ខ្ញុំមិននឹកស្មានថាអ្នកណាម្នាក់ពូកែបាញ់ស្មើលោកទេ ។ យ៉ាកុំហ្វារ កូនលោក ពូកែបាញ់ដូចលោកទេ ? » អ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام ឆ្លៀតយកឱកាសនេះប្រកាសរំលឹកចំពោះមហាជនថាព្រះអង្គ صلوات الله عليه والسلام ជាអ្នកណា ហើយអ្នកណាជាអាស្ហ៍លុល-បៃត៍ عليهم السلام ថា៖ « យើង អាស្ហ៍លុល-បៃត៍ យើងទទួលពីម្នាក់ទៅម្នាក់ នូវសុក្រឹតភាពនិងភាពពេញលេញ ដែលអល់ឡោះហ៍ عزّ وجلّ បានដាក់ចុះមកលើព្រះសាស្តា صلى الله عليه وآله وسلم ព្រះអង្គ عزّ وجلّ ដោយមានព្រះបន្ទូលថា៖ « ថ្ងៃនេះអញបានធ្វើឲ្យសាសនាពួកអ្នកសុក្រឹតឥតខ្ចោះសម្រាប់ពួកអ្នក បានបង្គ្រប់ឧបការធម៌អញលើពួកអ្នក ហើយ





ឃើញក្រុមគ្រិស្តសាសនិកកំពុងរង់ចាំមុខទ្វារ អ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام បានសួរថាមានរឿងអ្វីកើតឡើង ? ព្រះអង្គ صلوات الله عليه والسلام ក៏បានដឹងថានោះគឺពួកអ្នកកាន់សាសនាគ្រិស្ត ដែលកំពុងតែរង់ចាំសម្តេចសង្ឃរបស់ពួកគេចេញមកជួបមហាជនមួយឆ្នាំម្តងដើម្បីឆ្លើយសំណួរ ។ អ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام ចាំជាមួយគ្រិស្តសាសនិកជនទាល់តែសម្តេចសង្ឃចេញមក ។ លុះសម្តេចសង្ឃមកដល់ បានឃើញអ៊ីម៉ាំក៏បានយល់ភ្លាមថាព្រះអង្គមិនមែនជាគ្នារបស់ខ្លួនទេ ហើយបានសួរថាតើព្រះអង្គជាគ្រិស្តសាសនិកឬជាមុស្លីម ។ ព្រះអង្គបានតបវិញថាព្រះអង្គជាមុស្លីម ។ សម្តេចសង្ឃចង់ដឹងថាព្រះអង្គជាមុស្លីមដែលមានចំណេះឬបុគ្គលសាមញ្ញគ្មានចំណេះ ។ បន្ទាប់ពីបានដឹងថាព្រះអង្គជាបុគ្គលដែលមានចំណេះចេះដឹង សម្តេចសង្ឃប៉ងបន្តុះបង្អាប់ព្រះអង្គដោយសំណួរពិបាកឆ្លើយ ក្នុងលក្ខណៈសម្ញែងឲ្យគេឃើញ ដោយមានក្រុមគ្រិស្តសាសនិកជួយគាំទ្រ គឺគ្រិស្តសាសនិកដែលកាន់តែណាយចិត្តពីសាសនារបស់ដូនតារបស់ខ្លួន ។ សម្តេចសង្ឃបានថា៖

-តើលោកបកស្រាយបានទេថាអ្នកឋានសួគ៌ស៊ីផឹកតែមិននោម ?

-ទារកនៅក្នុងពោះម្តាយក៏ដូច្នេះដែរ ។ វាស៊ីតែមិនបញ្ចេញទេ ។

-លោកស្គាល់ពេលមួយទេ ដែលមិនមែនពេលថ្ងៃ មិនមែនពេលយប់ ?

-ពេលមួយដែលនៅក្នុងចន្លោះពេលមុនថ្ងៃរះ (សេតារុន) និងពេលថ្ងៃរះ ។ ពេលនេះ ហើយដែលអ្នកជម្ងឺបានស្ងប់ អ្នកអត់ងងុយដេកលក់ ។

-ចូរប្រាប់ខ្ញុំអំពីមនុស្សពីរនាក់ដែលកើតថ្ងៃដូចគ្នា ស្លាប់ថ្ងៃដូចគ្នា តែម្នាក់មានអាយុ ១៥០ ឆ្នាំពេលស្លាប់ ឯម្នាក់ទៀតមានអាយុតែ ៥០ ឆ្នាំទេនៅពេលស្លាប់ ?

-អ៊ូស្ហែរនិងប្អូនប្រុស ។ កាលមានអាយុ ២៥ អ៊ូស្ហែរបានដើរកាត់តាមភូមិមួយដែលបាក់បែកខ្ទេចខ្ទីគ្មានសល់អ្វីឡើយ ។ អ៊ូស្ហែរបានថា៖ «តើអល់ឡោះហ៍ عزوجل នឹងធ្វើឲ្យដីនេះរស់ឡើងវិញបានដូចម្ដេចទៅ បន្ទាប់ពីវាបានស្លាប់ទៅហើយនោះ ? (ស៊.២ អា.២៥៩)» អល់ឡោះហ៍ عزوجل បានឲ្យអ៊ូស្ហែរស្លាប់អស់មួយសតវត្សរ៍ ហើយព្រះអង្គ عزوجل បានឲ្យអ៊ូស្ហែររស់វិញ ។ អ៊ូស្ហែរត្រឡប់មកវិញដោយមានយុវវ័យ មករស់នៅជាមួយប្អូនដែលមានវ័យជរា ។ អ្នកទាំងពីរបានរស់នៅជុំគ្នាអស់ ២៥ ឆ្នាំ ហើយបានស្លាប់ថ្ងៃតែមួយ ។

ភ្ញាក់ផ្អើល សម្ដេចសង្ឃយល់ថាបុរសរូបនេះ ដែលស្គាល់អាថ៌កំបាំងដែលពុំមានអ្នកណាស្គាល់ក្រៅពីពួកសម្ដេចសង្ឃទេនោះ មិនមែនអ្នកណាក្រៅពី



បុគ្គលដែលក្ដាប់នូវអភិញ្ញាទេ ។ សម្ដេចសង្ឃក៏បានផ្លាស់សាសនាមកកាន់សាសនាអ៊ីស្លាម បណ្ដាលឲ្យមានគ្រិស្តសាសនិកមួយចំនួនធំផ្លាស់សាសនា ។

## ការប្រលងបាញ់

ខ៉ុលិហ្វអ៊ូម៉ៃយ៉ាស់ទាំងឡាយមិនអាចអត់ទ្រាំមើលអ៊ីម៉ាំអាស់លុល-បៃត៍ عليهم السلام ល្បីកេរ្តិ៍ឈ្មោះបានទេ តែក៏មិនអាចរាំងរាបានឡើយ ។ ក៏ប៉ុន្តែហ៊ីស្ហាំ ខ៉ុលិហ្វអប្រិយរូបនេះបានក្នុកគំនិតមួយថា អ៊ីម៉ាំត្រឹមត្រូវស្របច្បាប់របស់សហគមន៍មុស្លីមប្រាកដជាមានចំណុចខ្សោយ ។ ដោយដឹងថាអ៊ីម៉ាំអាស់លុល-បៃត៍ عليهم السلام មិន មានពេលនិងមិនមានសីលធម៌ទាបថោកដើរបរបាញ់សត្វ ឬហាត់បាញ់ធ្នូទេនោះ ហ៊ីស្ហាំបានរៀបចំពិធីប្រកួតបាញ់ធ្នូយ៉ាងអ៊ឹកធឹកមួយ បានអញ្ជើញអ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام និងបុត្រ صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام អ៊ីម៉ាំយ៉ាក់ហ្វារ صلوات الله عليه والسلام មកចូលរួម ហើយបានឲ្យអ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام បាញ់ ។ អ៊ីម៉ាំបានរំលឹកហ៊ីស្ហាំថាព្រះអង្គ صلوات الله عليه والسلام ចាស់ណាស់ហើយ មិនអាចបញ្ចេញកាយពលកម្មបែបនេះបានទេ ។ តែហ៊ីស្ហាំទទូចសូមហើយ បានបញ្ជាឲ្យអភិជនគួរយ៉ស់ម្នាក់យកធ្នូនិង គ្រាប់ព្រួញមកឲ្យព្រះអង្គ صلوات الله عليه والسلام ។ ហ៊ីស្ហាំខំប្រឹងសង្កេតមើលទិដ្ឋភាពក្នុងបំណងបន្តុះបង្អាប់អ៊ីម៉ាំនៅពី